# مدرسة اهل البيت

# សាលា
# អាស្ហ៊ុល-បៃត៏

## សៀវភៅ ហ្វីក្កោះហ្ស៍ ថ្នាក់ទី ១ (អាយុ ៥-៦ ឆ្នាំ)

រ៉ស៊្វលុលឡោះហ្ស៍ صلى الله عليه وآله وسلم មានព្រះវចនៈថា៖ "ការស្វែងរកចំណេះវិជ្ជាជាកាតព្វកិច្ចរបស់មុស្លីមីនប្រុសស្រីគ្រប់រូប ។"

## សិក្សាសាសនា

# បញ្ជីមាតិកា

មេរៀនទី ១ - អល់ឡោះហ្ទ៍ (ﷲ) ........................................ ៣
មេរៀនទី ២ - بِسْمِ اللهِ الرَّحْمٰنِ الرَّحِيْمِ........................................ ៥
មេរៀនទី ៣ - កាលីម៉ាស្ហ៍ (كلمة) លំដាប់ដំបូងបង្អស់ ........................................ ៨
មេរៀនទី ៤ - កាលីម៉ាស្ហ៍ (كلمة) - លំដាប់ទី ២ ........................................ ១០
មេរៀនទី ៥ - កាលីម៉ាស្ហ៍ (كلمة) - លំដាប់ទី ៣ ........................................ ១២
មេរៀនទី ៦ - កាលីម៉ាស្ហ៍ (كلمة) - លំដាប់ទី ៤ ........................................ ១៤
មេរៀនទី ៧ - កាលីម៉ាស្ហ៍ (كلمة) - លំដាប់ទី ៥ ........................................ ១៦
មេរៀនទី ៨ - កាលីម៉ាស្ហ៍ (كلمة) ........................................ ១៨
មេរៀនទី ៩ - ស្ហ៍ឡាវ៉ាត ........................................ ១៩
មេរៀនទី ១០ - អល់ឡ៍ហ្ហូ អាគ្ក៉ុបារ (الله أكبَر) ........................................ ២២
មេរៀនទី ១១ - ស្ហ៍ឡាត្ហ៍ (صلاة) ........................................ ២៥
មេរៀនទី ១២ - ស្ហ៍ឡាត្ហ៍ - គ្គីយ៉ាម ........................................ ២៨
មេរៀនទី ១៣ - ស្ហ៍ឡាត្ហ៍ - តាក់ប៊ីរ៉ទុល អិះហ្រ៉ារ៉ម ........................................ ៣០
មេរៀនទី ១៤ - ស្ហ៍ឡាត្ហ៍ - រូគុអ៊ុ៍ (رُكوع) ........................................ ៣២
មេរៀនទី ១៥ - ស្ហ៍ឡាត្ហ៍ - សាច្ជ៍ដ្ជាស្ហ៍ (سجدة) ........................................ ៣៤
មេរៀនទី ១៦ - ស្ហ៍ឡាត្ហ៍ - យ្ហ៉ុលុស ........................................ ៣៦
មេរៀនទី ១៧ - ស្ហ៍ឡាត្ហ៍ - គ្គុនូត ........................................ ៣៨
មេរៀនទី ១៨ - កាយវិការក្នុងស្ហ៍ឡាត្ហ៍ ........................................ ៤០

## មេរៀនទី ១

# អល់ឡោះហ៍ (ﷲ)

មានតែព្រះមួយគត់ ព្រះនាមរបស់ព្រះអង្គគឺ **អល់ឡោះហ៍** (ﷲ) ។

អល់ឡោះហ៍ជាអ្នកណា ?

- ព្រះអង្គបានបង្កើតយើងទាំងអស់គ្នា និងបានបង្កើតអ្វីៗសព្វគ្រប់ដែលមាននៅជុំវិញយើង ។ ព្រះអង្គជាព្រះដែលបង្កើតយើង ។

- ព្រះអង្គគឺព្រះដែលមើលមកយើង ។ ព្រះអង្គជាព្រះអភិបាលយើង ។

- ព្រះអង្គគឺព្រះដែលយើងសូមជំនួយ ។
ព្រះអង្គជាព្រះជំនួយរបស់យើង ។

- ព្រះអង្គគឺព្រះដែលយើងស្តាប់បង្គាប់ ។ ព្រះអង្គជាព្រះម្ចាស់យើង ។

- ព្រះអង្គគឺព្រះដែលយើងនឹងវិលទៅរកវិញ ។ ព្រះអង្គគឺអល់ឡោះហ៍ ។

# កិច្ចការសិស្ស ១

ចូរទន្ទេញមេសូត្រឲ្យចាំរត់មាត់ ហើយផាត់ព័ណ៌នៅលើគំនូរ ។

អល់ឡោះហ្វ៍ជាព្រះដែលបង្កើតអ្វីៗសព្វគ្រប់ !












# មេរៀនទី ២

بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

(ខ្ញុំចាប់ផ្ដើម) ដោយព្រះនាមអល់ឡោះហ្ម៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។

យើងទាំងអស់គ្នាគប្បីថា بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ មុននឹងធ្វើមួយព្រោះយើងចង់ឲ្យអល់ឡោះហ្ម៍ជួយជ្រោមជ្រែងយើងក្នុងគ្រប់ទង្វើ ។

បើយើងថា بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ អល់ឡោះហ្ម៍នឹងដេញស្ទៃត្តនឆ្ងាយពីយើង វាមិនអាចមកបំផ្លិចបំផ្លាញកិច្ចការរបស់យើងបានទេ ។

ក្នុងសម័យថ្ងៃមួយ ស្ត្រីជាភរិយាម្នាក់តែងតែថា بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ មុនចាប់ផ្ដើមធ្វើអ្វីមួយ ។

រៀងរាល់យប់ មុនចូលដំណេកគាត់ដោះចិញ្ចៀនគាត់ទុកក្នុងប្រអប់វា ។ យប់មួយ ដូចសព្វមួយដងដែរ មុននឹងដោះចិញ្ចៀនគាត់ គាត់ថា៖

بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ ។

ស្វាមីគាត់មិនជឿទេថា អល់ឡោះហ្ម៍មិនអាចជួយជ្រោមជ្រែងយើងបានទេគ្រាន់តែថា بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ នោះ ។ យប់នោះ ដើម្បីបង្ហាញភរិយាគាត់ឲ្យដឹងថាពុំមានអ្វីប្លែកទេពេលសូត្រ بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ នោះ គាត់បានយក

ចិញ្ចៀនភរិយាគាត់ចេញពីប្រអប់វាទៅចោលក្នុងស្ទឹង ។

ព្រឹកឡើងស្ត្រីជាភរិយាប្រញាប់ទៅផ្សារពេក ក៏ពុំបានយកចិញ្ចៀនចេញពីប្រអប់វាមកពាក់វិញទេ ។

គាត់បានទិញត្រីមួយនៅឯផ្សារសម្រាប់ធ្វើម្ហូបពេលល្ងាច ។ មកដល់ផ្ទះវិញគាត់បានកាត់ត្រី ដើម្បីយកទៅធ្វើម្ហូប ។ តើអ្នកគិតថាគាត់ឃើញមានអ្វីនៅក្នុងពោះត្រីនោះ ?
មែន នៅក្នុងពោះត្រីនោះមានចិញ្ចៀនមួយវង់ ចិញ្ចៀនដែលស្វាមីគាត់បានចោលទៅក្នុងស្ទឹង ។ ត្រីបានលេបចិញ្ចៀនមួយវង់នេះទៅក្នុងពោះវា ។

ស្ត្រីជាភរិយាភ្ញាក់ផ្អើលអនេក ដែលបានឃើញចិញ្ចៀនគាត់នៅក្នុងពោះត្រី ។ លុះស្វាមីគាត់ត្រឡប់មកផ្ទះវិញ គាត់ក៏បានថ្លែងព្រឹត្តិការណ៍នេះប្រាប់ប្តី ។

បុរសជាស្វាមីរន្ធត់ចិត្តអនេក ។ បន្ទាប់មក គាត់បានសារភាពប្រាប់ភរិយាគាត់ថាគាត់បានចោលចិញ្ចៀនភរិយាគាត់ទៅក្នុងស្ទឹង ។ គាត់បានសារភាពដែរថាគាត់ស្តាយក្រោយ ហើយពេលនេះទើបគាត់ជឿជាក់ថាអល់ឡោះហ្ ការពារអ្នកណាដែលថា بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ ។

**ឧត្តមគតិរឿងនេះគឺៈ**

ចូរសូត្រ بِسْمِ اللَّهِ الرَّحْمَٰنِ الرَّحِيمِ ជានិច្ចមុននឹងធ្វើអ្វីមួយ ដើម្បីអល់ឡោះហ្ នឹងជួយការពារយើង ។ ពេលណាអល់ឡោះហ្ ការពារយើង ពេលនោះពុំមានអ្នកណាអាចធ្វើបាបយើងបានឡើយ ។

## កិច្ចការសិស្ស ២

# بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ

(ខ្ញុំចាប់ផ្តើម) ដោយព្រះនាមអល់ឡោះហ៍ ព្រះដ៏មានព្រះមេត្តាធម៌ ព្រះដ៏មានព្រះមេត្តាករុណាប្រណី ។



ចូរគូររូបវត្ថុនានាចំនួនបី គម្បីចាប់ផ្តើមដោយសូត្រ بِسْــمِ اللّٰهِ الرَّحْمٰنِ الرَّحِيْمِ ។

## មេរៀនទី ៣

# កាលីម៉ាស្ម៉ (كلمة) - លំដាប់ដំបូងបង្អស់

# لَا اِلٰهَ اِلَّا اللهُ

**ពុំមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ**

មានតែព្រះមួយគត់ ព្រះនាមរបស់ព្រះអង្គគឺអល់ឡោះហ្វ៍ ។

អល់ឡោះហ្វ៍គឺព្រះដែលយើងគោរពបូជា ។

អល់ឡោះហ្វ៍គឺព្រះដែលយើងបួងសួង ។

អល់ឡោះហ្វ៍បានបង្កើតយើងទាំងអស់គ្នា ។ ដូច្នេះព្រះអង្គទ្រង់ញាណនូវអ្វីដែលល្អប្រសើរសម្រាប់យើង ដូច្នេះហើយបានជាយើងត្រូវតែស្តាប់បង្គាប់ព្រះអង្គនិងធ្វើតាមព្រះអង្គ ។

អល់ឡោះហ្វ៍ការពារយើង ព្រះអង្គស្រឡាញ់យើងណាស់ ។

ពុំមានព្រះផ្សេងពីអល់ឡោះហ្វ៍ឡើយ ។

# កិច្ចការសិស្ស ៣

ចូរផាត់ព័ណ៌លើលេខខាងក្រោមនេះ ដោយសូត្រសាឡើងវិញរឿយៗថា៖

لَا اِلٰهَ اِلَّا اللّٰهُ

**ពុំមានព្រះផ្សេងពីអល់ឡោះហ្៍ឡើយ**



## មេរៀនទី ៤

# កាលីម៉ាស្ញ (كلمة) - លំដាប់ទី ២

# مُحَمَّدٌ رَّسُوْلُ اللهِ

### មូហាំម៉ាដ្ញ ﷺ ជាព្រះសាស្តារបស់អល់ឡោះហ៍

ព្រះសាស្តាមូហាំម៉ាដ្ញ ﷺ បានបង្ហាត់បង្រៀនយើងនូវអ្វីដែលអល់ឡោះហ៍តាអាឡាអនុញ្ញាតឲ្យយើងធ្វើ និងអ្វីដែលព្រះអង្គហាមមិនឲ្យយើងធ្វើ ។

ព្រះសាស្តាមូហាំម៉ាដ្ញ ﷺ បានបង្ហាត់បង្រៀនយើង ឲ្យចេះនមស្ការអល់ឡោះហ៍តាអាឡា និងចេះធ្វើអំពើល្អដើម្បីបំពេញព្រះហឫទ័យអល់ឡោះហ៍តាអាឡា ។ បើយើងប្រតិបត្តិតាមអ្វីៗ ទាំងអស់ដែលព្រះសាស្តាមូហាំម៉ាដ្ញ ﷺ បានបង្ហាត់បង្រៀនយើង យើងនឹងទៅជាមុស្លីមល្អ ។

ព្រះសាស្តានានាជាគ្រូដែលអល់ឡោះហ៍តាអាឡាបានបញ្ជូនមក ដើម្បីបង្ហាញយើងនូវរបៀបបែបជាមុស្លីមល្អ ។
ព្រះសាស្តានានាដឹងអ្វីៗទាំងអស់ ហើយមិនធ្វើអំពើណាមួយដែលអល់ឡោះហ៍តាអាឡាមិនគាប់ព្រះហឫទ័យឡើយ ។
មានព្រះសាស្តាច្រើនមកហើយ (១២៤ ០០០ អង្គ) ។
ព្រះសាស្តាដំបូងបង្អស់គឺ អាដាំ عليه السلام ។
ព្រះសាស្តាចុងក្រោយបង្អស់គឺ មូហាំម៉ាដ្ញ ﷺ ។

# កិច្ចការសិស្ស ៤

## مُحَمَّدٌ رَّسُوْلُ اللّٰهِ

**មូហាំម៉ាដ្ឋ ﷺ ជាព្រះសាស្ដារបស់អល់ឡោះហ៍**



ព្រះសាស្ដាដំបូងបង្អស់គឺ អាដាំ ។

ព្រះសាស្ដាចុងក្រោយបង្អស់គឺ មូហាំម៉ាដ្ឋ ﷺ ។



## មេរៀនទី ៥

# កាលីម៉ាស្ហ៍ (كلمة) - លំដាប់ទី ៣

# عَلِيٌّ وَلِيُّ اللهِ

**អ៊ីម៉ាំអាលីﷷ ជាទីស្រឡាញ់របស់អល់ឡោះហ៍**

អល់ឡោះហ៍តាអាឡាទ្រង់សព្វព្រះហឫទ័យអ៊ីម៉ាំអាលី(ﷷ)ណាស់ ពីព្រោះព្រះអង្គﷷស្តាប់បង្គាប់អល់ឡោះហ៍តាអាឡាជានិច្ច ហើយមិនដែលធ្វើឲ្យអល់ឡោះហ៍តាអាឡាទ្រង់ព្រះពិរោធឡើយ ។

អល់ឡោះហ៍តាអាឡាបានជ្រើសរើសអ៊ីម៉ាំអាលីﷷជាគ្រូ បន្ទាប់ពីព្រះសាស្តាមូហាំម៉ាដ្ឋﷺ ។

អ៊ីម៉ាំអាលីﷷមិនមែនជាសាស្តាទេតែព្រះអង្គជាអ៊ីម៉ាំ ។ ព្រះសាស្តាមូហាំម៉ាដ្ឋﷺយើងជាសាស្តាចុងក្រោយបង្អស់ ។

អល់ឡោះហ៍តាអាឡាបានមានព្រះបន្ទូលមកកាន់ព្រះសាស្តាយើង គឺព្រះសាស្តាមូហាំម៉ាដ្ឋﷺ ថាឲ្យព្រះអង្គបង្ហាត់បង្រៀនបណ្តាមនុស្សនូវអ្វីៗសព្វគ្រប់ដែលអល់ឡោះហ៍តាអាឡាមានព្រះបំណងឲ្យមនុស្សដឹង ហើយបន្ទាប់ពីនោះ បណ្តាអ៊ីម៉ាំមានតួនាទីជាអ្នកជួយជ្រោមជ្រែងបណ្តាមនុស្ស និងមានតួនាទីជាអ្នករំលឹកព្រះរាជសារដល់បណ្តាមនុស្ស ។

# កិច្ចការសិស្ស ៥

ព្រមនឹងពេលដែលអ្នកផាត់ព័ណ៌លើរូបបេះដូងខាងក្រោមនេះ ចូរអ្នកថានិងចងចាំមួយឃ្លានេះគឺ៖

عَلِيٌّ وَلِيُّ اللهِ

**អ៊ីមុាំអាលី ﷵ ជាទីស្រឡាញ់របស់អល់ឡោះហ៍**



## មេរៀនទី ៦

# កាលីម៉ាស្ហ់ (كلمة) - លំដាប់ទី ៤

# وَصِيُّ رَسُوْلِ اللهِ

### អ៊ីម៉ុាំអុាលីعليه السلامជាអ្នកស្នងព្រះសាស្តារបស់អល់ឡោះហ៍

ក្រោយពីព្រះសាស្តាមូហ៊ុាំម៉ាដ្ញ់ﷺបានចូលទិវង្គត និងត្រឡប់ទៅរកអល់ឡោះហ៍តាអុាឡាវិញ អ៊ីម៉ុាំអុាលីعليه السلامជាគ្រូរបស់បណ្ដាមុស្លីម ។

អុាលីعليه السلامជាមេដឹកនាំរបស់មុស្លីម ហើយមុស្លីមទាំងអស់គ្នាត្រូវតែស្ដាប់ឱវាទអុាលីعليه السلام ។

ព្រះសាស្តាﷺបានបង្ហាត់បង្រៀនសាសនាអ៊ីស្លាមដល់បណ្ដាមនុស្ស ឯអ៊ីម៉ុាំអុាលីعليه السلامមានតួនាទីជាអ្នករំលឹកបណ្ដាមនុស្ស អំពីការអប់រំរបស់ព្រះសាស្តាﷺ ពេលណាពួកមុស្លីមបានភ្លេចឬមិនបានយល់សម្ដីរបស់ព្រះសាស្តាﷺ ។

ព្រះសាស្តាមូហ៊ុាំម៉ាដ្ញ់ﷺជាព្រះសាស្តាចុងក្រោយបង្អស់ ហើយបន្ទាប់ពីព្រះអង្គមានអ៊ីម៉ុាំអុាលីعليه السلام ។
អ៊ីម៉ុាំដំបូងបង្អស់គឺអ៊ីម៉ុាំអុាលីعليه السلام ។ អ៊ីម៉ុាំចុងក្រោយបង្អស់គឺអ៊ីម៉ុាំ មូហ៊ុាំម៉ាដ្ញ់ ម៉ាស្ញ៉ុឌីعليه السلام ។ ព្រះអង្គមានព្រះជន្មនៅឡើយ ហើយព្រះអង្គជាអ៊ីម៉ុាំរបស់សម័យកាលយើង ។

# កិច្ចការសិស្ស ៦

ចូរផាត់ព័ណ៌លើរូបផ្កាយខាងក្រោមនេះ ព្រមទាំងចងចាំក្នុងចិត្តថាមានអ៊ីម៉ាំ ១២ រូប ។

وَصِيُّ رَسُوْلِ اللّٰهِ

**អ៊ីម៉ាំអាលីﷺជាអ្នកស្នងព្រះសាស្តារបស់អល់ឡោះហ៍**



## មេរៀនទី ៧

# កាលីម៉ាស្ហ៍ (كلمة) - លំដាប់ទី ៥

# وَ خَلِيْفَتُهُ بِلَا فَصْلِ

### អ៊ីម៉ាំអាលីعليه السلامជាខ៊ុលិហ្វទីមួយ

ខ៊ុលិហ្វមានន័យថា មេដឹកនាំ អ្នកដែលមនុស្សស្តាប់ឱវាទ ។
អ៊ីម៉ាំអាលីعليه السلامជាមេដឹកនាំទីមួយរបស់បណ្តាមុស្លីម បន្ទាប់ពីព្រះសាស្តាមូហាំម៉ាដ្ឋ៍ﷺបានវិលត្រឡប់ទៅឯអល់ឡោះហ្វ៍តាអាឡាវិញ ។

មនុស្សអាក្រក់ដ៏ច្រើនបានអះអាងថាខ្លួនជាមេដឹកនាំ តែពួកគេជាមនុស្សខុស ព្រោះពួកគេមិនបានស្តាប់បង្គាប់អល់ឡោះហ្វ៍តាអាឡាទេ ។

អល់ឡោះហ្វ៍តាអាឡាបានជ្រើសរើសអ៊ីម៉ាំអាលីعليه السلام ជាមេដឹកនាំរបស់បណ្តាមុស្លីម ឲ្យពួកគេស្តាប់ឱវាទអ៊ីម៉ាំអាលីعليه السلام បន្ទាប់ពីព្រះសាស្តារបស់អល់ឡោះហ្វ៍តាអាឡា ។

មនុស្សល្អទាំងអស់បានតាមអ៊ីម៉ាំអាលីعليه السلام អ៊ីម៉ាំអាលីعليه السلامបានបង្ហាត់បង្រៀនជានិច្ចឲ្យពួកគេក្លាយទៅជាមុស្លីមល្អ និងគាប់ព្រះហឫទ័យអល់ឡោះហ្វ៍តាអាឡា ។
អ៊ីម៉ាំអាលីعليه السلامមានប្រាជ្ញាឈ្លាសវៃណាស់ ព្រះអង្គعليه السلامបានបង្ហាត់បង្រៀនបណ្តាមុស្លីម នូវអ្វីៗយ៉ាងច្រើន ។

## កិច្ចការសិស្ស ៧

ព្រមនឹងផាត់ព័ណ៌លើរូបខាងក្រោមនេះ ចូរចងចាំ៖

# وَ خَلِيْفَتُهُ بِلَا فَصْلِ

**អ៊ីម៉ាំអាលី عليه السلام ជាខ៉៍លិហ្វទីមួយ**




# ទី ១

## មេរៀនទី ៨

# កាលីម៉ាស់

لَا اِلٰهَ اِلَّا اللّٰهُ

ពុំមានព្រះផ្សេងពីអល់ឡោះហ៍ឡើយ

مُحَمَّدٌ رَّسُوْلُ اللّٰهِ

មូហាំម៉ាដ់ صلى الله عليه وآله وسلم ជាព្រះសាស្តារបស់អល់ឡោះហ៍

عَلِيٌّ وَّلِيُّ اللّٰهِ

អ៊ីម៉ាំអាលី عليه السلام ជាទីស្រឡាញ់របស់អល់ឡោះហ៍

وَصِيُّ رَسُوْلِ اللّٰهِ

អ៊ីម៉ាំអាលី عليه السلام ជាអ្នកស្នងព្រះសាស្តារបស់អល់ឡោះហ៍

وَ خَلِيْفَتُهُ بِلَا فَصْلِ

អ៊ីម៉ាំអាលី عليه السلام ជាខ៊ុលិហ្វទីមួយ

ចូរទន្ទេញកាលីម៉ាស់ឲ្យចាំស្ទាត់ ។

## មេរៀនទី ៩

# ស្វ៏ឡាវ៉ាត

اَللّٰهُمَّ صَلِ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

**អល់ឡោះហ៍អឺយ! សូមព្រះរាជទានសិរីសួស្តីមកលើព្រះសាស្តាមូហ៊ាំម៉ាដ់ និងអាស្ល់លុល-បៃត៍ (ក្រុមគ្រួសារ) ព្រះអង្គផង ។**

គេហៅក្រុមគ្រួសាររបស់ព្រះសាស្តាថា "អាស្ល់លុល-បៃត៍" ។ ក្រុមគ្រួសារនេះមានរាជបុត្រីរបស់ព្រះអង្គ គឺ ប៊ីប៊ី ហ្វាទីម៉ាស្ល់ سلام الله عليها និងអ៊ីម៉ាំទាំង ១២ អង្គ عليهم السلام ។

រាល់ពេលដែលអ្នកទាំងអស់គ្នាបានឮព្រះនាមរបស់ព្រះសាស្តា صلى الله عليه وآله وسلم និងរាជបុត្រីរបស់ព្រះអង្គ سلام الله عليها ពេលនោះអ្នកទាំងអស់គ្នាគប្បីសូត្រ ស្វ៏ឡាវ៉ាត ។

ពេលណាអ្នកទាំងអស់គ្នាបានឮព្រះនាមរបស់អ៊ីម៉ាំទី ១២ របស់យើង គឺអ៊ីម៉ាំមូហ៊ាំម៉ាដ់ អាល់-ម៉ាស្ល់ឌី عليه السلام អ្នកទាំងអស់គ្នាគប្បីសូត្រស្វ៏ឡាវ៉ាត ថែមទាំងងើបឈរ យកដៃស្តាំដាក់លើក្បាលហើយឱនក្បាលដើម្បីគោរពព្រះអង្គ ។ ព្រោះអ៊ីម៉ាំទី ១២ عليه السلام របស់យើងទ្រង់គង់ព្រះជន្មនៅឡើយ ។

ពេលណាអ្នកទាំងអស់គ្នានៅឯម៉ាស់យ៊ិដ្ឋ ហើយអ្នកទាំងអស់គ្នាមិនយល់ន័យឃុតបាស្ល់ ពេលនោះអ្នកទាំងអស់គ្នាគប្បីសូត្រស្វ៏ឡាវ៉ាតឲ្យច្រើន ។

ពេលដែលអ្នកទាំងអស់គ្នាសូត្រស្វ៏ឡាវាត អ្នកទាំងអស់គ្នាសូមឲ្យអល់ឡោះហ៍

តាអាឡាទ្រង់ព្រះរាជទាននូវសិរីសួស្តីមកឲ្យព្រះសាស្តាﷺ និងព្រះរាជកុលដ្ឋាន (គ្រួសារ) របស់ព្រះអង្គﷺ ។ អ៊ីនស្ហា-អល់ឡោះហ៍ នៅថ្ងៃគ្វីយ៉ាម៉ាត់ ព្រះសាស្តាﷺនិងព្រះរាជកុលដ្ឋានព្រះអង្គនឹងសូមឲ្យអល់ឡោះហ៍តាអាឡាលើកលែងទោសឲ្យអ្នកទាំងអស់គ្នាវិញ សម្រាប់គ្រប់ស្វ៊ឡាវ៉ាតដែលអ្នកទាំងអស់គ្នាបានសូត្រឲ្យព្រះអង្គទាំងអស់នោះ ។

## កិច្ចការសិស្ស ៩

# ស្វ៏ឡាវ៉ាត

اَللّٰهُمَّ صَلِ عَلٰى مُحَمَّدٍ وَّ اٰلِ مُحَمَّدٍ

**អល់ឡោះហ៍អឺយ! សូមព្រះរាជទានសិរីសួស្ដីមកលើព្រះសាស្ដាមូហាំម៉ាដ់ និងអាស្ស៎លុល-បៃត៍ (ក្រុមគ្រួសារ) ព្រះអង្គផង ។**

ចូរផាត់ព័ណ៌លើគ្រាប់ទាំង ១៤ ដែលមាននៅលើតាស់ប៊ិះហ៍ស្វ៏ឡាវ៉ាត ពិសេសសម្រាប់ព្រះសាស្ដាﷺនិងព្រះរាជកុលដ្ឋានព្រះអង្គ (ប៊ីប៊ី ហ្វាទីម៉ាស្ស៎ سلام الله عليها និងអ៊ីម៉ាំទាំង ១២ អង្គ ១+១+១២=១៤) នៅខាងក្រោមនេះ ។ ចូរសូត្រស្វ៏ឡាវ៉ាតសាចុះឡើង ក្នុងពេលផាត់ព័ណ៌លើ គ្រាប់តាស់ប៊ិះហ៍ ។



**មេរៀនទី ១០**

# អល់ឡ៍ហ្វ៊ អាក់ប៊ារ (اللهُ أَكْبَر)

អល់ឡ៍ហ្វ៊ អាក់ប៊ារ មានន័យថា អល់ឡោះហ្វ៍ធំថ្កើងបំផុត (លើសអ្វីៗទាំងអស់) ។

អល់ឡោះហ្វ៍បានបង្កើតអ្វីៗសព្វគ្រប់ ។

ព្រះអង្គបានបង្កើតពិភពលោក ។
ព្រះអង្គបានបង្កើតយើងគ្រប់គ្នា អ្នកទាំងអស់គ្នា ខ្ញុំ ម៉ែអ្នកទាំងអស់គ្នា ពុកនិងអ្នកឯទៀតទាំងអស់គ្នា ។
ព្រះអង្គបានបង្កើតសត្វ ។
ព្រះអង្គបានបង្កើតដើមឈើនិងផ្កា ។
ព្រះអង្គបានបង្កើតមេឃ ជាមួយថ្ងៃនិងខែ ។
ព្រះអង្គបានបង្កើតអ្វីៗទាំងអស់ ។
ព្រះអង្គធំថ្កើងណាស់ ។

អល់ឡោះហ្វ៍ខ្លាំងពូកែផងដែរ ។
ព្រះអង្គខ្លាំងពូកែលើសមនុស្សទាំងអស់ ។
ព្រះអង្គខ្លាំងពូកែលើសសត្វទាំងអស់ ។
ព្រះអង្គខ្លាំងពូកែលើសអ្វីៗទាំងអស់ ។
ព្រះអង្គធំថ្កើងណាស់ ។

អល់ឡោះហ៍ឆ្លាតបំផុត
ព្រះអង្គឆ្លាតលើសមនុស្សទាំងអស់
ព្រះអង្គធំថ្កើងណាស់ ។

អល់ឡោះហ៍មិនត្រូវការអ្នកណាទេ ។
យើងទាំងអស់គ្នាត្រូវការអល់ឡោះហ៍ ។
ព្រះអង្គធំថ្កើងណាស់ ។

ពេលណាអ្នកទាំងអស់គ្នាបានឃើញអ្វីមួយដែលធំសម្បើម និងអស្ចារ្យ ពេលនោះចូរអ្នកទាំងអស់គ្នាថា អល់ឡ៍ហ្វូ អាក់បារ (الله أَكْبَر) ព្រោះអល់ឡោះហ៍ធំថ្កើងលើសអ្វីៗដែលអ្នកទាំងអស់គ្នាបានឃើញនោះទៅទៀត ។

## កិច្ចការសិស្ស ១០

ចូរផាត់ព័ណ៌ដោយស្ងូត្រថា៖

# អល់ឡ៉ហ្ហ៊ូ អាក់បារ

(اَللّٰهُ اَكْبَرُ)




ធំថ្លើងបំផុត (លើសអ្វីៗទាំងអស់)

## មេរៀនទី ១១

# ស្វ៉ឡាត្ទ៍ (صلاة)

ស្វ៉ឡាត្ទ៍គឺការគោរពបូជា (នមស្ការ) អល់ឡោះហ្វ៍តាអាឡាប្រចាំថ្ងៃ ដែលមុស្លីមទាំងអស់ប្រតិបត្តិប្រាំដងក្នុងមួយថ្ងៃ ។

នៅក្នុងស្វ៉ឡាត្ទ៍ អ្នកទាំងអស់គ្នានិយាយរកអល់ឡោះហ្វ៍តាអាឡា ដូច្នេះអ្នកទាំងអស់គ្នាចូរប្រតិបត្តិឲ្យអស់ពីសមត្ថភាព ។ យកល្អឲ្យស្លៀកពាក់ស្អាត ឲ្យដុសធ្មេញ ឲ្យសិតសក់ ហាក់ដូចជាអ្នកទាំងអស់គ្នាទៅជួបលោកអ្នកធំណាម្នាក់អញ្ចឹងដែរ ។ អល់ឡោះហ្វ៍តាអាឡាសំខាន់ជាងសត្វលោកទាំងអស់ទៅទៀត ។

មុននឹងបំពេញស្វ៉ឡាត្ទ៍ (នមស្ការ) អ្នកទាំងអស់គ្នាត្រូវធ្វើ វ៉ូឌុអ៊្ (وضوء) សិន ។ នេះគឺរបៀបលាងសម្អាតមួយពិសេសដែលព្រះសាស្តាﷺបានបង្ហាត់យើង ។

អ្នកទាំងអស់គ្នាអាចនិយាយរកអល់ឡោះហ្វ៍តាអាឡាបាន ពេលណាក៏បានដែរ ស្រេចតែអ្នកទាំងអស់គ្នា អ្នកទាំងអស់គ្នាមិនបាច់រង់ចាំឲ្យដល់ពេលស្វ៉ឡាត្ទ៍ (នមស្ការ)សិនទេ ។

ស្វ៉ឡាត្ទ៍ជាមធ្យោបាយនិយាយរកអល់ឡោះហ្វ៍តាអាឡា ដែលព្រះសាស្តាﷺ បានបង្រៀនយើង ។ នេះជារបៀបពិសេសមួយ ដូច វ៉ូឌុអ៊្ (وضوء) ដែលជារបៀបលាងសម្អាតពិសេសមួយដែរនោះ ។

ពេលបំពេញស្វ៉ឡាត្ទ៍ (នមស្ការ) យើងត្រូវផ្តោតអារម្មណ៍ទៅរកអល់ឡោះហ្វ៍

តាអ៊ុទ្បាតែមួយគត់ និងយកចិត្តទុកដាក់លើអ្វីដែលយើងកំពុងតែសូត្រក្នុងស្ម័ទ្បាត្ត៍យើងនោះ ។ យើងគប្បីបំពេញស្ម័ទ្បាត្ត៍យើតៗនិងច្បាស់លាស់ យើងគប្បីធ្វើនមស្ការនៅពេលដែលបានកំណត់ស្រេចហើយ ដ្បិតយើងមិនត្រូវបង្អែបង្អង់ទៅនិយាយរកអល់ទ្បោះហ្វ៍តាអ៊ុទ្បាទេ ពីព្រោះយើងស្រឡាញ់អល់ទ្បោះហ្វ៍តាអ៊ុទ្បាណាស់ ។

## កិច្ចការសិស្ស ១១

ចូរគូរពេលធ្វើស្វ៍ឡាត្ដុំថ្ងៃរសៀលពិសេសនៅលើនាឡិកាខាងក្រោមនេះ ដែលអ្នកបានធ្វើនៅឯសាលា ។




ចូរផាត់ព័ណ៌លើនាឡិកានេះ ។

## មេរៀនទី ១២

# ស្វ៏ឡាត់ - គីយ៉ាម

មុនចាប់ផ្ដើមប្រតិបត្តិស្វ៏ឡាត់ អ្នកទាំងអស់គ្នាត្រូវប្រតិបត្តិគីយ៉ាម ។

គីយ៉ាមគឺវិធីឈរពិសេសក្នុងពេលបំពេញស្វ៏ឡាត់ ។

គីយ៉ាមប្រុសនិងគីយ៉ាមស្រីខុសគ្នា ។

រូបខាងក្រោមនេះបង្ហាញត៏លិប និងត៏លីបាស៊ុ ប្អូនស្រីរបស់ត៏លិបកំពុងឈរគីយ៉ាម ។



ត៏លិប



ត៏លីបាស៊ុ

| ត៏លិប | ត៏លីបាស៊ុ |
|---|---|
| ១) កន្ទែកប្រអប់ជើងបន្តិច | ១) ប្រអប់ជើងជិតគ្នា |
| ២) សំយុងដៃតាមដងខ្លួន | ២) ---------- |
| ៣) ស្រោមដៃរួមគ្នា | ៣) ---------- |
| ៤) ដាក់ភ្នែក (មើលទៅឯទូរបាស៊ុ) | ៤) ---------- |
| ៥) ទម្លាក់ស្មា | ៥) ---------- |

## កិច្ចការសិស្ស ១២

ឲ្យប្រុសៗផាត់ព័ណ៌លើរូបភាពប្រុសលិបកំពុងឈរត្រៀមយ៉ាម ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបភាពស្រីបាស់កំពុងឈរត្រៀមយ៉ាម ។



ចូរគូសរង្វង់មូលត្រង់ចំណុចទាំង ៥ ដែលបានរៀនរួចហើយ (ប្រអប់ជើង ដៃ ម្រាមដៃ ភ្នែក ស្មា) ។

## មេរៀនទី ១៣

# ស្វ៍ឡាត់ - តាក់ប៊ីរ៉ទុល អិះហ៊្រ៉ាម

ដើម្បីចាប់ផ្ដើមប្រតិបត្តិស្វ៍ឡាត់ អ្នកទាំងអស់គ្នាត្រូវឈរត្រង់យ៉ាម បន្ទាប់មកសូត្រតាក់ប៊ីរ៉ទុល អិះហ៊្រ៉ាម ។

តាក់ប៊ីរ៉ទុល អិះហ៊្រ៉ាម ជាការសូត្រថា អល់ឡ៉ហ៊ូ អាក់ពារ ទីមួយដែលអ្នកទាំងអស់គ្នាសូត្រនៅក្នុងស្វ៍ឡាត់ ។ គេសូត្រ តាក់ប៊ីរ៉ទុល អិះហ៊្រ៉ាម នេះក្រោយពី នៀតរួច (គឺក្រោយពីបាននឹកក្នុងចិត្តថាចង់ធ្វើអ្វី និងធ្វើដើម្បីអ្នកណា) ។

ក្នុងពេលសូត្រ តាក់ប៊ីរ៉ទុល អិះហ៊្រ៉ាម នេះ អ្នកទាំងអស់គ្នាត្រូវលើកដៃទាំងពីរ ឡើងឲ្យមេដៃនៅក្រោយត្រចៀក ។

ពេលណាអ្នកទាំងអស់គ្នាសូត្រថា អល់ឡ៉ហ៊ូ អាក់ពារ ពេលនោះស្វ៍ឡាត់ របស់អ្នកទាំងអស់គ្នាចាប់ផ្ដើមហើយ ។

ត៍លិបនិងប្អូនស្រីគេកំពុងតែសូត្រ តាក់ប៊ីរ៉ទុល អិះហ៊្រ៉ាមៈ



ត៍លិប

១) កន្ធែកប្រអប់ជើងបន្តិច
២) លើកដៃដល់ត្រចៀក (មេដៃនៅក្រោយត្រចៀក)
៣) ដាក់ភ្នែក (មើលទៅឯត្លួរបាស៊ូ)



ត៍លីបាស៊ូ

១) ប្រអប់ជើងជិតគ្នា
២) -------------
៣) -------------

## កិច្ចការសិស្ស ១៣

ឲ្យប្រុសៗផាត់ព័ណ៌លើរូបក្មេងប្រុសកំពុងឈរតគ្នីយ៉ាមសូត្រ តាក់ប៊ីរ៉ទុល អិះហ្រ៉ាម ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបក្មេងស្រីបាស់កំពុងឈរតគ្នីយ៉ាមសូត្រ តាក់ប៊ីរ៉ទុល អិះហ្រ៉ាម ។



ចូរគូសរង្វង់មូលត្រង់ចំណុចទាំង ៣ ដែលបានរៀនរួចហើយ (ប្រអប់ជើង ដៃ ភ្នែក) ។

## មេរៀនទី ១៤

# ស្ឡាត់ - រូគុអ៍ (رُكوع)

ក្នុងការបំពេញស្ឡាត់ បន្ទាប់ពីបានឈរត្ហីយ៉ាមហើយ អ្នកទាំងអស់គ្នាត្រូវរូគុអ៍ ។

រូគុអ៍គឺការឱន ចាត់ទុកថាត្រូវបើពាក់កណ្ដាលខ្លួនអ្នកកោង ។

រូគុអ៍ប្រុសនិងរូគុអ៍ស្រីខុសគ្នា ។

ខាងក្រោមនេះ រូបតូ៏លិបនិងប្អូនគេកំពុងរូគុអ៍៖





| តូ៏លិប | តូ៏លីបាស៊ុ |
|---|---|
| ១) កន្ទែកប្រអប់ជើងបន្តិច | ១) ប្រអប់ជើងជិតគ្នា |
| ២) ដាក់ដៃលើជង្គង់ | ២) -------- |
| ៣) សម្លឹងមើលក្រោម (មើលជើង) | ៣) -------- |
| ៤) សន្ទឹងជើង (ជើងត្រង់) | ៤) មិនសន្ទឹងជើងទេ |
| ៥) ខ្នងរាបស្មើ | ៥) -------- |

## កិច្ចការសិស្ស ១៤

ឲ្យប្រុសៗផាត់ព័ណ៌លើរូបគំនូរបក្ខលិបកំពុងរុគុអ៍ ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបគំនូរបក្ខលីបាស់កំពុងរុគុអ៍ ។





ចូរគូសរង្វង់មូលលើចំណុចទាំង ៥ ដែលបានរៀនរួចហើយ (ប្រអប់ជើង ដៃ ភ្នែក ជើង ខ្នង) ។

## មេរៀនទី ១៥

# ស្ញ៏ទ្បាត់ - សាច់ដ្ញាស់ (سجدة)

បន្ទាប់ពីបានរូគុអ៍ហើយ អ្នកត្រូវឈរត្ញីយ៉ាម បន្ទាប់មកទើបធ្វើសាច់ដ្ញាស់ ។

សាច់ដ្ញាស់គឺការក្រាបដោយឲ្យថ្ងាសប៉ះផ្ទៃកម្រាល ព្រមទាំងបាតដៃ ជង្គង់ និងមេជើងផង ។

ក្នុងរ៉ក់អ៊ាស់(ركعة)នីមួយៗមានពីរស្ញ៉ូយ៉ូដ្ កាត់ចែកដោយ យ្ញ៉ូលុស មួយ ។

សាច់ដ្ញាស់ប្រុសនិងសាច់ដ្ញាស់ស្រីខុសគ្នា ។

នៅលើរូបនេះ ត៏្លិបនិងប្អូនស្រីកំពុងក្រាបសាច់ដ្ញាស់ ។



ត៏្លិប

១) ប្រអប់ជើងឃ្លាតគ្នាបន្តិច
(មេជើងប៉ះផ្ទៃកម្រាល)

២) ភ្នែកសម្លឹងទៅចុងច្រមុះ

៣) កែងដៃមិនប៉ះផ្ទៃកម្រាល
(ឃ្លាតពីដងខ្លួនបន្តិច)



ត៏្លីបាស់

១) ប្រអប់ជើងជិតគ្នា
(មេជើងប៉ះផ្ទៃកម្រាល)

២) ------------

៣) កែងដៃប៉ះផ្ទៃកម្រាល
(មិនឃ្លាតពីដងខ្លួនទេ)

(ម្រាមដៃជិតគ្នា តម្រង់ទៅរកត្ញីបទ្បាស់ ក្បែរត្រចៀក)

## កិច្ចការសិស្ស ១៥

ឲ្យប្រុសៗផាត់ព័ណ៌លើរូបតុ៊លិបកំពុងក្រាបសាច់ដ្វាស់ ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបតុ៊លីបាស់កំពុងក្រាបសាច់ដ្វាស់ ។





ចូរគូសរង្វង់មូលលើចំណុចទាំង ៣ ដែលបានរៀនរួចហើយ ទាក់ទងនឹង ប្រអប់ជើង ម្រាមដៃ ថ្ងាស ភ្នែក កែងដៃ ។

ចូរគូសរង្វង់មូលលើចំណុចទាំង ៧ ដែលត្រូវតែប៉ះផ្ទៃកម្រាលក្នុងពេលក្រាប សាច់ដ្វាស់ ដោយដាក់ព័ណ៌ខុសគ្នា ។

**មេរៀនទី ១៦**

# ស្វ៏ទ្បាត់ - យ្ជុលុស

ក្នុងចន្លោះពីរស្ជ៍យ្ជុដ្ទ មានយ្ជុលុសមួយ ។

យ្ជុលុសគឺការអង្គុយ ។

នៅលើរូបនេះ ត៏្វលិបនិងប្អូនស្រីកំពុងអង្គុយយ្ជុលុស ។



ត៏្វលិប ត៏្វលីបាស៊ូ

១) ដាក់ប្រអប់ជើងស្តាំលើប្រអប់ជើងឆ្វេង ១) -------------

២) ដាក់ដៃលើភ្លៅ ២) -------------

៣) ភ្នែកសម្លឹងមើលទៅឯទូរបាស៊ូ ៣) -------------

# កិច្ចការសិស្ស ១៦

ឲ្យប្រុសៗផាត់ព័ណ៌លើរូបភាពសិស្សប្រុសកំពុងអង្គុយយ៉ូលុស ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបភាពសិស្សស្រីកំពុងអង្គុយយ៉ូលុស ។





ចូរគូសរង្វង់មូលលើចំណុចទាំង ៣ ដែលបានរៀនរួចហើយ ទាក់ទងនឹង ប្រអប់ជើង ដៃ ភ្នែក ។

## មេរៀនទី ១៧

# ស្ហ៏ឡាត់ - គ្ហុនូត

ក្នុងរ៉ក់អ៊ាស់ទី ២ នៅពេលកំពុងឈរគ្ហីយ៉ាម ពេលស្ហ៏ឡាត់ គប្បីសូត្រគ្ហុនូតមុននឹងរូគុអ៊ ។

គ្ហុនូតគឺការលើកដៃឡើង ដោយលាតប្រអប់ដៃឆ្ពោះទៅឯមេឃ ។

នៅលើរូបនេះ ត៏លិបនិងប្អូនស្រីកំពុងសូត្រគ្ហុនូត ។



ត៏លិប



ត៏លីបាស់

១) ប្រអប់ជើងឃ្លាតគ្នាបន្តិច ១) ប្រអប់ជើងជិតគ្នា

២) ដាក់ដៃចំពីមុខ បាតដៃលាតទៅឯមេឃ ប្រអប់ដៃនិងម្រាមដៃជាប់គ្នា

៣) ភ្នែកសម្លឹងមើលប្រអប់ដៃ ៣) -----------------

# កិច្ចការសិស្ស ១៧

ឲ្យប្រុសៗផាត់ព័ណ៌លើរូបក្មេងលិបកំពុងឈរស្មូត្រឌូអា ។
ឲ្យស្រីៗផាត់ព័ណ៌លើរូបក្មេងលីបាស់កំពុងឈរស្មូត្រឌូអា ។



ចូរគូសរង្វង់មូលលើចំណុចទាំង ៣ ដែលបានរៀនរួចហើយ ទាក់ទងនឹងប្រអប់ជើង ប្រអប់ដៃ ភ្នែក ។

## មេរៀនទី ១៨

# កាយវិការក្នុងស្វ៏ទ្បាត់



គាក់ប៊ីរ៉ទុល អិះហ្វ៉ារ៉ម គ្វីយ៉ាម រូគុអ៍ គ្វីយ៉ាម សាចុ៉ដ្ហាស៊ុ យូ៉លុស



សាចុ៉ដ្ហាស៊ុ យូ៉លុស គ្វីយ៉ាម គ្វូនូត រូគុអ៍ គ្វីយ៉ាម



សាចុ៉ដ្ហាស៊ុ យូ៉លុស សាចុ៉ដ្ហាស៊ុ យូ៉លុស (ចប់)



តាក់បីរ៉ទុល អិះហ្រ៉ាម គ្ហីយ៉ាម រ្គុអ៊ុ គ្ហីយ៉ាម សាច់ដ្ជាស៊ូ



យ្ជុលុស សាច់ដ្ជាស៊ូ យ្ជុលុស គ្ហីយ៉ាម



គុនូត រ្គុអ៊ុ គ្ហីយ៉ាម សាច់ដ្ជាស៊ូ យ្ជុលុស



សាច់ដ្ជាស៊ូ យ្ជុលុស (ចប់)

កំណែលើកទី ២, 06/2020